クメール語

សម្រាប់ឆ្នាំ
២០២៤

# ចាប់ផ្ដើមជ្រើសរើសសិស្សចូលរៀន សម្រាប់ថ្នាក់អនុវិទ្យាល័យពេលយប់

潤水都市 さがみはら

## សាខាសាលាអនុវិទ្យាល័យអូណូមិណាមិ ទីក្រុងសាហ្គាមិហារ៉ា

ទីកន្លែង៖ក្នុងទីធ្លានៃវិទ្យាល័យកាណាហ្គាវ៉ា សូហ្គូ សានគ្យូ ខេត្តកាណាហ្គាវ៉ា (១-១១-១ បឺនខ្យូ មិណាមិខឺ ក្រុងសាហ្គាមិហារ៉ា)

**បើកបវេសនកាលថ្មីនៅខែមេសា ឆ្នាំ២០២៤**



## ការណែនាំស្ដីអំពីការធ្វើបទបង្ហាញសម្រាប់អ្នកមានបំណងចូលរៀន (Nyuugaku-kibousha-setsumei-kai)

បទបង្ហាញសម្រាប់អ្នកមានបំណងចូលរៀននឹងត្រូវធ្វើឡើងសម្រាប់អ្នកដែលមានបំណងចូលរៀនថ្នាក់អនុវិទ្យាល័យពេលយប់។
សម្រាប់អ្នកដែលរស់នៅក្នុងភូមិស្រុកនៅក្នុងខេត្តកាណាហ្គាវ៉ា (មិនរាប់បញ្ចូលទីក្រុងយូកូហាម៉ា ទីក្រុងកាវ៉ាសាគិ) អាចចូលរួមបាន។

- **លើកទី១** ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣ (សុក្រ) ម៉ោង ៦ល្ងាច
- **លើកទី២** ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៣ (អង្គារ) ម៉ោង ៦ល្ងាច
- **លើកទី៣** ថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣ (ពុធ) ម៉ោង ៦ល្ងាច
- **លើកទី៤** ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៣ (សុក្រ) ម៉ោង ៦ល្ងាច

※ការចុះយកព័ត៌មានរបស់ប្រព័ន្ធផ្សព្វផ្សាយអាចធ្វើបានតែលើកទី១ប៉ុណ្ណោះ។

**ទីតាំង ថ្នាក់រៀននៃសាខាសាលាអូណូមិណាមិទីក្រុងសាហ្គាមិហារ៉ា** (នៅក្នុងវិទ្យាល័យកាណាហ្គាវ៉ា សូហ្គូ សានគ្យូ ខេត្តកាណាហ្គាវ៉ា)




※អ្នកដែលមានបំណងចូលរៀន សូមចូលរួមការធ្វើបទបង្ហាញមួយក្នុងចំណោមបួន
※ប្រសិនបើ មិនអាចចូលរួមបានសូម្បី១ដង សូមធ្វើការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាអប់រំទីក្រុងសាហ្គាមិហារ៉ា។
※ដើម្បីចូលរួមការធ្វើបទបង្ហាញបាន ចាំបាច់ត្រូវធ្វើការចុះឈ្មោះជាមុន។ (មើលនៅផ្នែកខាងក្រោយ)
សូមធ្វើការចុះឈ្មោះដោយខ្លួនឯងផ្ទាល់ ឬដោយដៃគូរបស់អ្នក។
※សូមពិភាក្សានៅពេលចុះឈ្មោះប្រសិនបើអ្នកត្រូវការការបកប្រែនៅថ្ងៃនោះ។

| | | |
|---|---|---|
| Night Junior High School<br>Escuela Secundaria Nocturna<br>Junior High School para sa gabi<br>初中夜校<br>야간 중학 | 夜間中学 (や かん ちゅう がく) | Escola Ginasial Noturna<br>Trường trung học cơ sở ban đêm<br>रात्रि कनिष्ठ उच्च विद्यालय<br>रात्री जुनियर हाई स्कूल<br>អនុវិទ្យាល័យពេលយប់<br>มัธยมศึกษาตอนต้นภาคค่ำ |



# លក្ខខ័ណ្ឌនៃការចូលរៀន

អ្នកដែលមានសិទ្ធចូលរៀនគឺជាអ្នកដែលគឺជាអ្នកដែលគ្រប់អាយុចូលរៀនបាន(អ្នកដែលកើតត្រឹមថ្ងៃទី១ខែមេសាឆ្នាំ២០០៩)ហើយចាំបាច់ត្រូវតែមានចំណុចណាមួយពី១ដល់៣។

១ អ្នកដែលមានអាយុចូលរៀនតែមិនអាចបញ្ចប់កាតព្វកិច្ចអប់រំបាន

២ អ្នកដែលបញ្ចប់ថ្នាក់អនុវិទ្យាល័យដោយមិនបានទទួលការអប់រំគ្រប់គ្រាន់ដោយសារហេតុផលផ្សេងៗ។

៣ ជនជាតិបរទេស និងអ្នកផ្សេងទៀតដែលមិនបានទទួលការអប់រំស្មើនឹងកាតព្វកិច្ចអប់រំនៅប្រទេសជប៉ុន។

# អនុវិទ្យាល័យវេនយប់គឺជាកន្លែងបែបនេះ

- ជាថ្នាក់សិក្សាវេនយប់របស់អនុវិទ្យាល័យឯកជន
- គ្មានការចំណាយលើការសិក្សា។
  សៀវភៅពុម្ពទាំងអស់ផ្តល់ជូនដោយមិនគិតថ្លៃ ។
- គ្រូតាមមុខវិជ្ជានីមួយៗ នៅអនុវិទ្យាល័យជាអ្នកបង្រៀន។
- ម៉ោងសិក្សាចាប់ផ្តើមពីម៉ោង ៥ល្ងាច បញ្ចប់នៅម៉ោង ៩យប់។
  ម៉ោងសិក្សាមានរាល់ថ្ងៃចាប់ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ។
- បន្ទាប់ពីបញ្ចប់ការសិក្សានៅអនុវិទ្យាល័យវេនយប់ អ្នកអាចទទួលបានសញ្ញាប័ត្របញ្ចប់ការសិក្សានៅថ្នាក់អនុវិទ្យាល័យ។

## កម្មវិធីសិក្សាមួយថ្ងៃសម្រាប់ថ្នាក់អនុវិទ្យាល័យវេនយប់

៤:២៥ ដល់ ៥:១០ ល្ងាច ថ្នាក់ត្រៀមមុនចាប់ផ្តើម (សម្រាប់តែអ្នកមានបំណង)

៥:១៥ ដល់ ៥:២០ ល្ងាច ថ្នាក់ចាប់ផ្តើម

៥:២៥ ដល់ ៦:១០ ល្ងាច ម៉ោងទី១ (៤៥នាទី)

៦:២០ ដល់ ៧:០៥ យប់ ម៉ោងទី២ (៤៥នាទី)

៧:១៥ ដល់ ៨:០០ យប់ ម៉ោងទី៣ (៤៥នាទី)

៨:១០ ដល់ ៨:៥៥ យប់ ម៉ោងទី៤ (៤៥នាទី)

៨:៥៥ ដល់ ៩:០០ យប់ ថ្នាក់បញ្ចប់



## ស្តីអំពីបទបង្ហាញសម្រាប់អ្នកមានបំណងចូលរៀន (Nyuugaku-kibousha-setsumei-kai)

### ១ ខ្លឹមសារនៃបទបង្ហាញ

(១) គារវកិច្ចរបស់ក្រុមប្រឹក្សាអប់រំទីក្រុងសាហ្គាមិហារ៉ា

(២) ការពន្យល់អំពីអនុវិទ្យាល័យវេនយប់

(៣) វគ្គសំណួរ និងចម្លើយ

(៤) ការពិគ្រោះយោបល់ជាបុគ្គល

### ២ ស្តីអំពីការចុះឈ្មោះទុកជាមុន

(១) របៀបចុះឈ្មោះ

- តាមរយៈទូរស័ព្ទ ឬក៏តាមរយៈការិយាល័យផ្តល់ព័ត៌មាន
  ថ្ងៃធ្វើការ ចាប់ទទួលពីម៉ោង ៩ព្រឹករហូតដល់ម៉ោង ៥ល្ងាច
- តាមរយៈទូរសារ ឬ តាមរយៈអ៊ីម៉ែលEnglish available
  សូមផ្ញើដោយបំពេញខ្លឹមសារដូចខាងក្រោម
  ① ឈ្មោះអ្នកមានបំណងចូលរៀន ② អាស័យដ្ឋាន
  ③ លេខទូរស័ព្ទ ④ បទបង្ហាញដែលមានបំណងចូលរួម
  (⑤ ប្រសិនបើមានអ្នកមកជាមួយ ឈ្មោះអ្នកមកជាមួយ)
  ⑥ ថាតើអ្នកចង់បានការបកប្រែឬអត់
  ※ អ្នកមកជាមួយជាគោលការណ៍គឺម្នាក់

(២) រយៈពេលនៃការចុះឈ្មោះ

ថ្ងៃទី៣ ខែកក្កដាឆ្នាំ ២០២៣ (ច័ន្ទ)ដល់ ថ្ងៃទី១១ ខែតុលា (ពុធ)

※ការចុះឈ្មោះគឺទទួលរហូតដល់មុនថ្ងៃនៃការប្រារព្ធបទបង្ហាញនីមួយ

## 【លំដាប់លំដោយរហូតដល់ការចូលរៀន】

១ ចូលរួមការធ្វើបទបង្ហាញ (ចូលឲ្យបាន ១ដង)
(ថ្ងៃទី១៤ ខែកក្កដា, ថ្ងៃទី៥ ខែកញ្ញា, ថ្ងៃទី៤ ខែតុលា, ថ្ងៃទី១៣ ខែតុលា)

▼

២ សូមពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋានដែលអ្នករស់នៅជាមុន

▼

៣ ការរៀបចំពាក្យសុំចូលរៀន

▼

៤ ដាក់ពាក្យសុំចូលរៀននៅទីក្រុងសាហ្គាមិហារ៉ា sagamihara (រហូតដល់ចុងខែតុលា)

បទពិសោធន៍ការប្រឡងចូលរៀន(អ្នកមានបំណង)
(ថ្ងៃទី៣០ខែតុលា, ថ្ងៃទី៣១ខែតុលា, ថ្ងៃទី១ខែវិច្ឆិកា, ថ្ងៃទី២ខែវិច្ឆិកា)

៥ សម្ភាសន៍នៅសាលា(ក្នុងកំឡុងខែវិច្ឆិកា)

▼

៦ ផ្តល់ដំណឹងលទ្ធផលសម្ភាសន៍→ការសម្រេចចិត្តចូលរៀន



## ទីកន្លែងចុះឈ្មោះ ទីកន្លែងផ្តល់ព័ត៌មាន

ក្រុមប្រឹក្សាអប់រំទីក្រុងសាហ្គាមិហារ៉ាផ្នែកអប់រំសាលា
លេខទូរស័ព្ទ 042-704-8918 ទូរសារ 042-758-9036
អ៊ីម៉ែល gakkokyouiku@city.sagamihara.kanagawa.jp